# រាជបណ្ឌិត្យសភាកម្ពុជា

# ភាពសុខដុមរនានៃក្រុមជនជាតិភាគតិចចិននៅកម្ពុជា



ផ្ទាំងចម្លាក់លើជញ្ជាំងរោងទងប្រាសាទបាយ័នបង្ហាញអំពីកងទ័ពជនជាតិភាគតិចចិនចេញទៅធ្វើចម្បាំងជាមួយកងទ័ពខ្មែរ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧

*ចងក្រងនិងរៀបរៀង ដោយ៖*


*លោក* **ហៀង លាងហុង**

*ប្រធានផ្នែកវប្បធម៌វិទ្យា វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ*

*នៃរាជបណ្ឌិត្យសភាកម្ពុជា*



-២០១៨-

# ភាពសុខដុមរមនានៃក្រុមជនជាតិភាគតិចចិននៅកម្ពុជា

អ្នករៀបរៀងអត្ថបទ

**ហៀង លាងហុង** ប្រធានផ្នែកវប្បធម៌វិទ្យា

វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា

Email: leanghongh75@gmail.com

*ក្រុមជនជាតិភាគតិចចិន បានធ្វើអន្តោប្រវេសន៍មកជ្រកកោនក្នុងប្រទេសកម្ពុជា ប្រហែលតាំងពីដើមដំបូងនៃប្រវត្តិសាស្ត្រមកម្ល៉េះ។ មានកត្តាជាច្រើនដែលជំរុញឱ្យមានវត្តមានជនជាតិចិនជាច្រើននៅលើទឹកដីកម្ពុជា។ ជនជាតិចិនទទួលបានបទពិសោធន៍យ៉ាងច្រើនពីរបត់នៃប្រវត្តិសាស្ត្រខ្មែរ។ ភាពឈ្លាសវៃប្រែកបដោយភាពបត់បែន ការសម្របខ្លួន និងការតស៊ូស្វិតស្វាញក្នុងវិស័យជំនួញបានធ្វើឱ្យជនជាតិចិនតែងតែទទួលបានជោគជ័យក្នុងការស្ថាបនាក្រុមគ្រួសារ និងក្រុមសង្គមជនជាតិភាគតិចចិនដ៏រឹងមាំនិងសុខសាន្តនៅលើទឹកដីកម្ពុជាស្ទើរគ្រប់សម័យកាល។*

## ១-ប្រវត្តិសង្ខេបអំពីក្រុមជនជាតិភាគតិចចិននៅកម្ពុជា

ជនជាតិចិន ឬខ្មែរកាត់ចិន ឬកូនចៅចិន ជាជនជាតិភាគតិចមួយ ដែលបានភៀសខ្លួនពីស្រុកចិនមករស់នៅលើទឹកដីនៃប្រទេសកម្ពុជា។ វចនានុក្រមខ្មែរ (១៩៦៧:១៩៧) បានពន្យល់ថា *«ចិនជាជាតិមនុស្សមួយប្រភេទមានដើមកំណើតនៅប្រទេសចិនឬមកពីប្រទេសចិនមកនៅក្នុងប្រទេសកម្ពុជា»*។ តាមឯកសារប្រវត្តិសាស្ត្រកម្ពុជាក្នុងសតវត្សដំបូងៗ ដូចជាកំណត់ត្រារបស់បេសកទូតជនជាតិចិន លោក ម៉ា ទួន លីន លោក ជីវ តាក្វាន់ ភស្តុតាងបុរាណវត្ថុវិទ្យា ចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័នជាឧទាហរណ៍ និងឯកសារបរទេសផ្សេងៗទៀត អ្នកស្រាវជ្រាវអាចសន្និដ្ឋានថា ជនជាតិចិនប្រហែលមកដល់ប្រទេសកម្ពុជាតាំងពីសតវត្សទី១នៃគ.ស. (J. Boisselier 989:15)។ អ្នកស្រាវជ្រាវខ្លះទៀតបានអះអាងថា ទំនាក់ទំនងការទូតប្រទេសចិននិងកម្ពុជា បានចាប់ផ្តើមនៅរវាងឆ្នាំ២២៥-៣៣០នៃគ.ស.។ តាំងពីពេលនោះមក អន្តោប្រវេសន៍ជនជាតិចិនមកកាន់ប្រទេសកម្ពុជាក៏បានកើតឡើងជាបន្តបន្ទាប់ដល់សតវត្សក្រោយៗ (W. Willmott 1966:16)។



⬅ ផ្ទាំងចម្លាក់លើជញ្ជាំងរោងទងប្រាសាទបាយ័នបង្ហាញអំពីកងទ័ពជនជាតិភាគតិចចិនចេញទៅធ្វើចម្បាំងជាមួយកងទ័ពខ្មែរ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧



៤ ផ្ទាំងចម្លាក់លើជញ្ជាំងរោងទងប្រាសាទបាយ័ន បង្ហាញអំពីស្ត្រីជនជាតិភាគតិចចិន បានយកជង្វាយទៅថ្វាយស្ត្រីក្នុងរាជវង្ស ឬស្ត្រីជាភរិយាមន្ត្រីជាន់ខ្ពស់ខ្មែរ។ ចម្លាក់ទាំងនេះបានបញ្ជាក់ឱ្យយើងយល់ពីភាពបត់បែន ការសម្រប ការបញ្ច្របខ្លួន និងការទំនាក់ទំនងដ៏ឈ្លាសវៃនៃជនជាតិភាគតិចចិនជាស្ត្រី ឬបុរស តាំងពីសម័យបុរាណកាល។ ឥរិយាបថទន់ភ្លន់បែបនេះបានឱ្យពួកគេអាច រួមរស់នៅលើទឹកដីកម្ពុជាប្រកបដោយសុខដុមរមនា ហើយវប្បធម៌បែបនេះក៏នៅតែបន្តរហូតបច្ចុប្បន្ន។

ជនភៀសខ្លួនជនជាតិចិនដែលមកកាន់កម្ពុជា ភាគច្រើនមានដើមកំណើតចេញមកពីទីជនបទប្រទេសចិន ហើយមូលហេតុដែលនាំឱ្យជនជាតិចិនមកកាន់ប្រទេសកម្ពុជា ដោយសារពួកគេបានលក់កម្លាំងពលកម្មឱ្យក្រុមគ្រួសារជនជាតិចិនជាអ្នកមាន ការបង្ខិតបង្ខំចុះកិច្ចសន្យាលក់កម្លាំងពលកម្មឱ្យភ្នាក់ងារអាណានិគម សង្គ្រាម ក្នុងតំបន់រស់នៅរបស់ពួកគេ ការរត់ភៀសខ្លួនចេញពីការឈ្លានពានរបស់កងទ័ពជប៉ុន គេចចេញពីកាតព្វកិច្ចយោធា ទឹកជំនន់ គ្រោះទុរ្ភិក្ស ជាដើម (ផេន្នី អេដ្វឺដ្ស ២០០៩:១៧៣)។ បើយោងតាមការកកត់សម្គាល់របស់ ជីវ តាក្វាន់ កត្តាភូមិសាស្ត្រ ធនធានធម្មជាតិ និងសង្គមខ្មែរនាពេលនោះ ក៏អាចជាចំណែកទាក់ទាញដល់ជនភៀសខ្លួនចិនមករស់នៅធ្វើជីវិតលើទឹកដីកម្ពុជាផងដែរ៖

> *«ពួកជនជាតិចិនដែលជាអ្នកស៊ីឈ្នួលដើរសំពៅកាលមកដល់ស្រុកនេះគេក៏ពេញចិត្តខ្លាំងណាស់ព្រោះស្រុកនេះមិនបាច់ប្រើសម្លៀកបំពាក់ច្រើន ហើយអង្ករក៏ស្រួលរក ប្រពន្ធក៏ស្រួលរកបាន ឯផ្ទះសំបែងក៏ស្រួលធ្វើគ្រឿងប្រើប្រាស់ក៏ងាយរក ការលក់ដូរក៏ធូរងាយ ម៉្លោះហើយបានជាមានអ្នកចូលពីស្រុកក្រោមករស់នៅស្រុកនេះច្រើនណាស់»*
> (លី ធាមតេង ១៩៧៣:៦៦)

ស្ត្រីខ្មែរក៏ប្រហែលជាហេតុផលមួយផ្សេងទៀត ដែលជំរុញលើកទឹកចិត្តដល់បុរសជនជាតិចិនជាច្រើនមកកម្ពុជា។ លោក ជីវ តាក្វាន់ បានសរសើរស្ត្រីខ្មែរថាពូកែរកស៊ី និងឧស្សាហ៍ព្យាយាម ដែលធ្វើឱ្យទាក់ទាញបុរសជនជាតិចិនចង់បានស្ត្រីខ្មែរមកធ្វើជាប្រពន្ធ៖

> *«អ្នកស្រុកនេះពួកស្រីៗប៉ិនជួញដូរណាស់ ហេតុនេះពួកចិនៗគេត្រូវរកប្រពន្ធមួយជាមុនសិនហើយនឹងបានចំណេញច្រើនដោយគេប៉ិនប្រសប់រកស៊ី...រាល់ថ្ងៃគេទៅលក់តាំងពីភ្លឺព្រាងៗដល់ពេលថ្ងៃត្រង់ទើបឈប់...»*
> (លី ធាមតេង ១៩៧៣:៥១)

នៅឆ្នាំ១៦២០ ជនជាតិភាគតិចចិន បានបង្កើតភូមិចិនមួយនៅក្នុងទីក្រុងភ្នំពេញ។ បុរសៗជនជាតិភាគតិចចិន បានយកនារីខ្មែរនិងចាមធ្វើជាប្រពន្ធ ដែលធ្វើឱ្យជីវិតពួកគេមួយផ្នែកធំចុះសម្រុងទៅនឹងសង្គមវប្បធម៌ខ្មែរ និងបានរស់នៅដោយសុខសាន្ត។ នៅរវាងសតវត្សទី១៨និង១៩ អន្តោប្រវេសន៍ជនជាតិចិន បានចូលមកប្រទេសកម្ពុជាច្រើនឡើង ហើយភាគច្រើនមកពីតំបន់ភាគឦសានប្រទេសចិន និងមានអប្បរភាសាខុសៗគ្នា (Willmott 1970 :6)។ ទោះបីមានការសិក្សាអំពីជនជាតិចិននៅប្រទេសកម្ពុជាច្រើនក្តី ប៉ុន្តែរហូតដល់បច្ចុប្បន្នមិនមានការបញ្ជាក់ឱ្យច្បាស់អំពីស្ថិតិជនជាតិភាគតិចចិនរស់នៅក្នុងប្រទេសកម្ពុជាមានចំនួនពិតប្រាកដប៉ុន្មាននៅឡើយ។ គេគ្រាន់តែអាចដឹងបានថាក្រុមជនជាតិភាគតិចចិន មកដល់បច្ចុប្បន្នមានចំនួន៥ក្រុមអប្បរធំៗផ្អែកលើភាសានិយាយ៖

**- ចិនទាជីវ**

ជនជាតិចិនទាជីវ មានស្រុកកំណើតនៅខេត្តក្វាងទុងនៃប្រទេសចិន (W. Wilmott 1970:7)។ គេឃើញចិនទាជីវរស់នៅទីក្រុងភ្នំពេញ ខេត្តកំពត និងខេត្តកំពង់ចាម។ មានជនភៀសខ្លួនចិនទាជីវរាប់ម៉ឺននាក់មករស់នៅកម្ពុជា ក្រោយពេលដែលប្រទេសសៀមដណ្តើមគ្រប់គ្រងបានខេត្តបាត់ដំបងនៅឆ្នាំ១៩៤១។ ចិនទាជីវ ច្រើនជាអ្នកមានមុខរបរខាងជំនួញពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្មតាមគ្រួសារ បើកហាងកាហ្វេ ធ្វើស្រែចំការ (ផេន្នី អេដ្វឺដ្ស ២០០៩:១៩២)។

**- ចិនកន្តាំង**

នៅទសវត្សរ៍ឆ្នាំ១៨៨០ ចិនកន្តាំងបានរីកធំឡើងនៅទីក្រុងភ្នំពេញ។ មកដល់ទសវត្សរ៍១៩៦០ ចិនកន្តាំងបានក្លាយទៅជាក្រុមជនជាតិភាគតិចចិនច្រើនជាងគេលំដាប់ទី១នៅកម្ពុជា។ ជនជាតិភាគតិចចិនកន្តាំងផ្តោតលើមុខរបរខាងសិប្បកម្ម និងសំណង់។

**- ចិនហៃណាំ**

ក្រុមជនជាតិភាគតិចចិនហៃណាំ មានប្រភពពីកោះហៃណាំប្រទេសចិន មកដល់កម្ពុជានៅឆ្នាំ១៦៧៥។ ចិនហៃណាំមានមុខរបរខាងឧស្សាហកម្មផលិតនំ ធ្វើចុងភៅ អ្នកលក់កាហ្វេ និងជាអ្នកបម្រើតាមផ្ទះឱ្យគ្រួសារជនជាតិអ៊ឺរ៉ុប រកស៊ីចងការប្រាក់ និងធ្វើកសិដ្ឋានដាំម្រេចធំៗ។

**- ចិនហុកកៀន**

ក្រុមជនជាតិភាគតិចចិនហុកកៀន ប្រហែលភៀសខ្លួនចេញពីខេត្តហ្វូចៀននៃប្រទេសចិន។ កូនចៅចិនហុកកៀនបាននិយាយតៗគ្នាថា ចិនហុកកៀន ជាក្រុមជនជាតិចិនដំបូងបង្អស់ដែលបានមកតាំងលំនៅក្នុងទីក្រុងភ្នំពេញ (Wilmott 1970:6)។ ជនជាតិចិនហុកកៀនភាគច្រើនមានមោទនភាពដោយ សារពួកគេមានការចុះសម្រុងគ្នាក្នុងការរួមរស់ក្នុងសង្គមខ្មែរជាងក្រុមជនជាតិភាគតិចចិនដទៃទៀត។ ចិនហុកកៀនបានបញ្ជូនកូនចៅទៅសាលារៀនខ្មែរដើម្បីក្លាយខ្លួនជាខ្មែរនិងបានចូលបម្រើការងាររាជការខ្មែរផង។

**- ចិនខិ ឬ ចិនហាក់កា**

ចិនខិ មានឈ្មោះដើមថា ហាក់កា (មានន័យថា ភ្ញៀវ ឬ គ្រួសារចម្លែក)។ គេមិនដឹងច្បាស់ថាក្រុមចិនខិចេញពីទីកន្លែងកំណើតណាឱ្យប្រាកដទេនៅប្រទេសចិន។ ប៉ុន្តែពួកគេបានតាំងទីលំនៅពាសពេញខេត្តក្វាងចូវ ហ្វូចៀន កៅហ៊្សូ ស៊្យាងហ៊្សី ក្វាងហ៊្សី កោះហៃណាំ ស៊ីផ័ន និងហ៊ូណាន់។ ពួកចិនខិបានកសាងកេរ្តិ៍ឈ្មោះល្បីល្បាញដោយសារពួកចិនខិបានក្លាយជារដ្ឋបុរសនិងជាអ្នកជំនួញល្បីល្បាញជាច្រើនរូប ដូចជា លោក តេង ស៊ាវពីង លោក លី ក្វាន់យូ លោក ស៊ុន យ៉ាត់សេន ជាដើម។ ម្យ៉ាងវិញទៀតភាពល្បីល្បាញនៃពួកចិនខិដោយសារតែភាពស្មោះត្រង់

ភាពអំណត់ក្នុងការងារ។ ពួកចិនខិបានចាត់ទុកពួកចិនដទៃទៀតថាជាអ្នកខ្ជិលច្រអូស គ្មានភាពស្មោះត្រង់ និងខ្ជះខ្ជាយ (ផេន្នី អេដ្វឺដ្ស ២០០៩:១៩៩)។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ចិនខិមានតួនាទីធំៗក្នុងវិស័យសេដ្ឋកិច្ច រួមមានជាងសំណង់ អ្នកដាំម្រេច ម្ចាស់កសិដ្ឋានគ្រឿងទេស អ្នករកស៊ីហាងបញ្ចាំរបស់របរ អ្នកលក់ថ្នាំពេទ្យ អ្នកធ្វើនំ និងអ្នកកាប់ឈើ។ ពួកចិនខិបានក្លាយជាផ្នែកមួយដ៏ល្អរបស់កម្ពុជា។

## ២-គោលនយោបាយចំពោះក្រុមជនជាតិភាគតិចចិនក្នុងបរិបទប្រវត្តិសាស្ត្រខ្មែរ

### សម័យអាណានិគមនិយមបារាំង (១៨៦៣ - ១៩៥៣)

ព្រះមហាក្សត្រខ្មែរដែលសោយរាជ្យជាបន្តបន្ទាប់តែងមានគោលនយោបាយ ផ្តល់សិទ្ធិជ្រកកោនដល់ជនភៀសខ្លួនជនជាតិចិននិងជនជាតិដទៃៗទៀតតាំងពីសតវត្សទី១៣មក។ នៅសតវត្សទី១៩ផ្អែកលើតម្លៃខាងវប្បធម៌ សេដ្ឋកិច្ច ភាពស្មោះត្រង់ និងចេះនិយាយភាសាខ្មែរបានល្អ ហើយបើពួកគេមានកំណើតនៅក្នុងប្រទេសកម្ពុជា កូនចៅជនជាតិភាគតិចចិនខ្លះក៏ត្រូវបានតែងតាំងធ្វើជាចៅហ្វាយខេត្តផងដែរ។ ពួកគេក៏ត្រូវបានលើកទឹកចិត្តឱ្យគោរព ប្រតិបត្តិទាំងវប្បធម៌ខ្មែរ និងការប្រតិបត្តិជំនឿសាសនាតាមបែបចិន។ ក្រោមការត្រួតពិនិត្យនិងគ្រប់គ្រងពីអាណានិគមបារាំង ជនជាតិភាគតិចចិនត្រូវបានហាមឃាត់មិនឱ្យចូលពាក់ព័ន្ធក្នុងកិច្ចការនយោបាយរបស់កម្ពុជា។ ពួកអាណានិគមបារាំងមិនសូវពេញចិត្តចំពោះក្រុមជនជាតិភាគតិចចិន ដោយហៅពួកចិនទាំងនោះថាជាអ្នកជំនួញដែលមានចំណង់ច្រើនហួសហេតុ ឬជាកម្មករដែលមានគំនិតមិនល្អ ដែលស្វែងរកសេចក្តីសុខរបស់ខ្លួនពីការជួញដូរអាភៀន ពីការលេងល្បែងស៊ីសង និងការចាប់ជំរិតជាដើម។ ម្យ៉ាងទៀតពួកអាណានិគមបារាំងបានមើលឃើញថាជនជាតិភាគតិចចិនមិនបានផ្តល់ប្រយោជន៍អ្វីសោះដល់ប្រទេសកម្ពុជា។ ផ្ទុយទៅវិញពួកគេបានបញ្ជូនប្រាក់ដែលរកបានទៅស្រុកកំណើតរបស់ខ្លួន។ នៅក្នុងក្រសែភ្នែកអាណានិគមបារាំង ជនជាតិភាគតិចចិនជាមនុស្សមានសារសំខាន់តិចតួចទោះបីពួកគេដឹងថាគំនិតធ្វើជំនួញ និងឧស្សាហកម្មរបស់ក្រុមជនជាតិភាគតិចចិន បានផ្តល់ទុនជួយឱ្យរបបអាណានិគមបារាំងមានដំណើរការទៅមុខក៏ដោយ។ ប៉ុន្តែក្រោយមកបារាំងប្តូរទស្សនៈនោះវិញ ដោយបានទទួលស្គាល់ជនជាតិភាគតិចចិនជាសហគមន៍រឹងមាំនៅបរទេសទៅវិញ ដែលផ្ទុយពីមុនធ្លាប់តែបានចាត់ទុកជនភៀសខ្លួនចិនជាសំណាត់អណ្តែតតាមទឹក ជាក្រុមចោរសមុទ្រ និងជាឧក្រិដ្ឋជន។ ការទទួលស្គាល់នេះក៏ជាហេតុជំរុញឱ្យជនជាតិភាគតិចចិនរស់នៅក្នុងប្រទេសកម្ពុជាក៏ដូចជារស់នៅតំបន់អាស៊ីអាគ្នេយ៍ និងដោយមានការគាំទ្រពីរដ្ឋាភិបាលរដ្ឋាភិបាលចិនផង ពួកគេបានចាប់ផ្តើមពង្រឹងអត្តសញ្ញាណវប្បធម៌ និងជំរុញឱ្យមានគំនិតជាតិនិយមខ្លាំងក្លាឡើង។

### សម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០)

ភាពសុខសាន្តរបស់ក្រុមជនជាតិភាគតិចចិននៅក្នុងសម័យអាណានិគមបារាំង បានប្រែប្រួលក្រោយពេលប្រទេសកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង។ ក្រុមជនជាតិភាគតិចនៅកម្ពុជាត្រូវស្ថិតក្រោមច្បាប់ពលរដ្ឋឆ្នាំ១៩៥៤ និងគោលនយោបាយសមាហរណកម្មជនជាតិភាគតិចនៅកម្ពុជាឱ្យទៅជាខ្មែរឆ្នាំ១៩៦៣។ បន្ទាប់មកគោលនយោបាយថ្មីមួយទៀតក្នុងការកំណត់សិទ្ធិមិនឱ្យជនជាតិភាគតិចចិនក្តោបក្តាប់របរកសិកម្ម និងជំនួញពាណិជ្ជកម្មនៅកម្ពុជា។ បញ្ហានេះបានជំរុញឱ្យជនជាតិភាគតិចចិនមួយចំនួន បានបង្ខំចិត្តភៀសខ្លួនទៅបរទេសនិងប្រទេសចិន។

ក្រោយការភ្ជាប់ទំនាក់ទំនងផ្លូវការរវាងប្រទេសចិននិងកម្ពុជា នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៥៦ មេដឹកនាំចិន លោក ជូ អេនឡាយ បានធ្វើទស្សនកិច្ចជាផ្លូវការនៅកម្ពុជា ហើយលោកបានប្រកាសលើកទឹកចិត្តចំពោះជនជាតិចិនឱ្យគោរពច្បាប់ ប្រពៃណី ទំនៀមទម្លាប់ សាសនា រៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិខ្មែរ និងធ្វើយ៉ាងណាដើម្បីឱ្យក្លាយជាជនជាតិខ្មែរ។ សេចក្តីណែនាំនេះគឺដើរស្របទៅនឹងគោលនយោបាយធ្វើសមាហរណកម្មជនជាតិភាគតិចឱ្យទៅជាខ្មែរដែលកំពុងអនុវត្តនៅកម្ពុជា។ ចាប់តាំងពីពេលនោះមក ក្រុមជនជាតិភាគតិចចិន ចាប់ផ្តើមបង្ហាញអត្តសញ្ញាណជនជាតិចិនតាមរយៈការបង្កើតសមាគមចិន សមាគមកីឡា សាលារៀនចិន ព្រះវិហារជាដើម។ ដោយការប្រែប្រួលខុសគ្នាខាងទស្សនៈនយោបាយរវាងចិននិងកម្ពុជា ចំណងមិត្តភាពរវាងប្រទេសទាំងពីរត្រូវបានបញ្ចប់ទៅវិញនៅក្នុងទសវត្សរ៍១៩៦៧។ ដូច្នេះស្ថានភាពរស់នៅរបស់ក្រុមជនជាតិភាគតិចចិន ក៏បានបត់បែនទៅតាមស្ថានការណ៍ជាក់ស្តែងនាពេលនោះដែរ។

**សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)**

រដ្ឋាភិបាលសម័យនេះបានរៀបចំគោលនយោបាយដើម្បីធ្វើបន្សុទ្ធក្រុមជនជាតិភាគតិចនៅកម្ពុជាទាំងអស់ឱ្យទៅជាខ្មែរ ដែលវាស្រដៀងគ្នាទៅនឹងគោលនយោបាយឆ្នាំ១៩៦៣ដែរ។ ក្រុមជនជាតិភាគតិចចិនបានប្រឈមជាមួយនឹងគោលនយោបាយនេះ ក្រោមការចោទប្រកាន់ថាជាអ្នកបង្កឱ្យបាត់បង់ទំនៀមទម្លាប់ និងសីលធម៌រស់នៅរបស់ខ្មែរព្រមទាំងជាអ្នកមានគំនិតផ្សព្វផ្សាយលទ្ធិកុំមុយនីសនៅកម្ពុជា។ ការប្រើប្រាស់ភាសាចិនក៏ត្រូវបានរឹតត្បិតបើសិនមាននិយាយនោះគឺជាការមិនគោរពចំពោះវប្បធម៌ខ្មែរ។ មជ្ឈមណ្ឌលវប្បធម៌សំខាន់ៗរបស់ខ្មែរ ជនជាតិភាគតិចចាម ជនជាតិភាគតិចចិន ដូចជា សាលារៀន ព្រះវិហារ វត្តអារាម ត្រូវបានបំផ្លិចបំផ្លាញក្នុងសង្គ្រាមរវាងឆ្នាំ១៩៧០និងឆ្នាំ១៩៧៣។

**សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)**

នៅចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ ដោគវាសនារបស់ជនជាតិខ្មែរ ក្រុមជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិចនៅកម្ពុជា រាប់លាននាក់ត្រូវបានសម្លាប់ដោយគ្មានកំហុសនិងដោយអយុត្តិធម៌ ក្រោមគោលនយោបាយរើសអើងប្រកាន់ពូជសាសន៍ វប្បធម៌ សាសនា និងនយោបាយាបាយ។

**សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨១)**

ក្រោយថ្ងៃរំដោះចេញពីរបប ប៉ុល ពត ក្រុមជនជាតិភាគតិចចិន ក៏ដូចជាក្រុមជនជាតិភាគតិចដទៃទៀតនៅកម្ពុជា គឺបានទទួលនូវសិទ្ធិថែរក្សាវប្បធម៌ អក្សរសាស្ត្រ និងភាសារបស់ពួកគេវិញ។ ពួកជនជាតិភាគតិចចិនបានប្រកបមុខរបរលក់ដូរឡើងវិញនៅតាមតំបន់ទីប្រជុំជននានា។ ប៉ុន្តែក្រោយមកមានការប្រែប្រួលបន្តិចនៅរវាងខែកុម្ភៈដល់ខែមិថុនាឆ្នាំ១៩៧៩ ដោយជនជាតិភាគតិចចិនគឺត្រូវបានរឹតបន្តឹងក្នុងការធ្វើជំនួញ ដែលបញ្ហានេះត្រូវបានគេគិតថាជាគោលនយោបាយបំបែកជនជាតិភាគតិចចិនឱ្យចេញឆ្ងាយពីជនជាតិខ្មែរ ក្រោមគោលនយោបាយនិងយុទ្ធសាស្ត្រនៃការគ្រប់គ្រងរបស់កងទ័ពវៀតណាម ដើម្បីប្រើប្រាស់ជនជាតិភាគតិចចិនធ្វើជាកូនអុកនយោបាយប្រឆាំងនឹងប្រទេសចិន (ផេន្នី អេដ្វឺដ្ស ២០០៩:២២៧)។

ជនជាតិភាគតិចចិនមួយចំនួនបានបង្ខំចិត្តភៀសខ្លួនទៅកាន់ប្រទេសថៃ និងផ្លាស់ទីទៅរស់នៅតាមជនបទនៃប្រទេសកម្ពុជា។ ការបង្រៀនភាសាចិន និងការប្រារព្ធពិធីទំនៀមទម្លាប់ចិន ការប្រើប្រាស់ឈ្មោះជាភាសាចិន ត្រូវស្ថិតក្នុងការហាមឃាត់។ អ្វីដែលជនជាតិភាគតិចចិននៅចងចាំគឺការអនុវត្ត «សារាចរ៣៥១» នាឆ្នាំ១៩៨៣ ក្នុងការចុះឈ្មោះជនជាតិចិនតាមផ្ទះនីមួយៗនៅទូទាំងប្រទេស។ សារាចរនេះបង្ហាញឱ្យឃើញពីការរើសអើងប្រកាន់

ជាតិសាសន៍ជាថ្មីទៀតបន្ទាប់ពីរបប ប៉ុល ពត។ ទោះបីយ៉ាងណាសារាចរ៣៥១ ក៏មិនត្រូវបានអនុវត្តទូលំទូលាយ និងហ្មត់ចត់ពេកទេ ប៉ុន្តែវាបានជះឥទ្ធិពលដល់ការបាត់បង់អត្តសញ្ញាណជាជនជាតិចិន ព្រោះមានក្រុមជនជាតិភាគតិចចិនជាច្រើនត្រូវរស់នៅលាក់ឈ្មោះ លាក់ត្រកូល ដោយប្រើគ្រប់មធ្យោបាយដើម្បីបង្ហាញខ្លួនថាជាជនជាតិខ្មែរ។ ស្ថានភាពរស់នៅរបស់ក្រុមជនជាតិភាគតិចចិនមានភាពធូរស្រាលនិងសេរីភាពឡើងវិញចាប់ពីឆ្នាំ១៩៨៥មក។

**សម័យរដ្ឋកម្ពុជា (១៩៨៩-១៩៩៣)**

ដោយសារការប្រែប្រួលផ្នែកនយោបាយក្នុងស្រុកនិងអន្តរជាតិ ការរើសអើងជាតិសាសន៍និងការរឹតបន្តឹងចំពោះជនជាតិភាគតិចចិនបានធូរស្រាល។ ចាប់ពីឆ្នាំ១៩៩០ដើម្បីផ្តាច់ការគាំទ្ររបស់ចិនចំពោះខ្មែរក្រហម រដ្ឋាភិបាលកម្ពុជាបានខិតខំកែលម្អនូវចំណងទាក់ទងជាមួយនឹងរដ្ឋាភិបាលចិន តាមរយៈការលើកកម្ពស់សិទ្ធិសេរីភាពរបស់សហគមន៍ជនជាតិភាគតិចចិន ដោយអាចបើកសាលារៀនចិន សមាគមជនជាតិចិន ការគោរពប្រតិបត្តិជំនឿសាសនានិងអត្តសញ្ញាណវប្បធម៌ផ្សេងៗរបស់ជនជាតិចិន ព្រមទាំងបានតែងតាំងឱ្យមានក្រុមប្រឹក្សាភិបាលអ្នកជំនួញជនជាតិចិននៅកម្ពុជាដោយមានភារកិច្ចសំខាន់ទៅលើកិច្ចការវប្បធម៌ចិន និងអនុញ្ញាតឱ្យជនជាតិភាគតិចចិនបានប្រារព្ធពិធីបុណ្យចូលឆ្នាំចិនឡើងវិញជាលើកដំបូងក្នុងឆ្នាំ១៩៩១។

**សម័យព្រះរាជាណាចក្រកម្ពុជា (១៩៩៣-បច្ចុប្បន្ន)**

មាត្រា៣១នៃរដ្ឋធម្មនុញ្ញដែលអនុម័តក្នុងឆ្នាំ១៩៩៣ បានចែងថា៖

*«ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ <u>ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម</u> ធនធាន ឬស្ថានភាពឯទៀតឡើយ...»*

ដូច្នេះក្នុងសម័យកាលនេះ ជនជាតិចិនបានទទួលនូវជំនឿចិត្តកក់ក្តៅ និងមានសិទ្ធិពេញលេញក្រោមគោលនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់សិទ្ធិសេរីភាពក្នុងការបង្ហាញនូវអត្តសញ្ញាណវប្បធម៌របស់ជនជាតិចិនតាមមធ្យោបាយផ្សេងៗ កាសែត សាលារៀនចិន សមាគមវប្បធម៌ និងព្រះវិហារសាសនា។ សមាគមចិនត្រូវបានបង្កើតឡើងវិញនៅតាមខេត្ត ក្រុង ភូមិ ស្រុកនានាទូទាំងប្រទេស។ នៅទីក្រុងភ្នំពេញក្រុមជនជាតិភាគតិចចិនទាំងប្រាំក្រុម បានបង្កើតសមាគមតាមអប្បូរភាសានីមួយៗ ដោយជ្រកក្រោមដំបូលនៃសមាគមជនជាតិចិននៅកម្ពុជា។

## ៣-ការពង្រឹងអត្តសញ្ញាណវប្បធម៌

សមាគមជនជាតិចិន សាលារៀនភាសាចិន ព្រះវិហារ គឺជាមធ្យោបាយចម្បងក្នុងការបង្ហាញអត្តសញ្ញាណវប្បធម៌ និងការរួមសាមគ្គីគ្នាយ៉ាងរឹងមាំនៃក្រុមជនជាតិចិននៅតាមតំបន់នីមួយៗ និងជាកន្លែងផ្ទេរចំណេះដឹងភាសានិងវប្បធម៌ទៅកូនចៅចិនជំនាន់ក្រោយៗ។

ជនជាតិភាគតិចចិនជាច្រើនយល់ថា អនាគតរបស់ពួកគេក៏ដូចជាអនាគតនៃប្រទេសកម្ពុជាដែរ ការបង្កើតសាលារៀនចិន គឺជាមធ្យោបាយមួយដែលពួកគេសង្ឃឹមថានឹងអាចជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា។

សាលារៀននឹងក្លាយទៅជាគ្រឹះដ៏រឹងមាំក្នុងការផ្ទេរចំណេះដឹងវប្បធម៌ចិនដល់អ្នកជំនាន់ក្រោយ។ ឆ្លងកាត់សង្គ្រាមអស់ជាច្រើនទសវត្សរ៍ ពួកចាស់ទុំជនជាតិចិនបានខិតខំកែលម្អវិស័យអប់រំរបស់ខ្លួនឡើងវិញយ៉ាងសកម្ម។ ទន្ទឹមនឹងការយល់ដឹងអំពីសារសំខាន់នៃភាសាចិន ដែលជាអត្តសញ្ញាណដ៏សំខាន់នៃជនជាតិចិនក្តី ប៉ុន្តែជនជាតិចិនក៏បានយល់ពីតួនាទីនិងតម្លៃនៃភាសាខ្មែរដែរ ដែលជាផ្នែកមួយជួយជំរុញឱ្យពួកគេអាចបញ្ជ្រាបខ្លួនចូលទៅក្នុងសង្គមខ្មែរលើគ្រប់វិស័យបានស្រួល។ ក្នុងទស្សនៈមិនខុសប៉ុន្មានពីគំនិតរបស់ជនជាតិចិនអំពីបញ្ហាភាសា មានជនជាតិខ្មែរមួយចំនួនក៏បានឱ្យតម្លៃ និងតួនាទីនៃការប្រើប្រាស់ភាសាចិននៅក្នុងការទំនាក់ទំនងសម្រាប់វិស័យជំនួញពាណិជ្ជកម្មដ៏សំខាន់មួយដែរ។ ដូច្នេះទើបបច្ចុប្បន្នគេសង្កេតឃើញ មានគ្រួសារខ្មែរបានបញ្ជូនកូនចៅរបស់ពួកគេទៅរៀនភាសាចិននៅសាលារៀនរបស់ចិនជាច្រើន។ ចំណែកគ្រួសារចិនវិញក៏បានបញ្ជូនកូនចៅទៅសិក្សានៅសាលារៀនខ្មែរផងដែរ។

កាសែតភាសាចិន ក៏បានដើរតួនាទីសំខាន់ដើម្បីពង្រីកនិងពង្រឹងសក្តានុពលអត្តសញ្ញាណវប្បធម៌ និងជំរុញវិស័យអប់រំខាងភាសាចិន ដោយបានជួយផ្សព្វផ្សាយនូវព័ត៌មានអត្ថបទជាភាសាចិនដែលសរសេរដោយកូនសិស្សក្មេងៗនិងសំណេររបស់គ្រូបង្រៀនភាសាចិន ព្រមទាំងចុះផ្សាយអត្ថបទរឿងនិទាន និងប្រវត្តិសាស្ត្រទាក់ទងនឹងវប្បធម៌ចិនផងដែរ។

ចំណងអាពាហ៍ពិពាហ៍រវាងជនជាតិភាគតិចចិនជាមួយជនជាតិខ្មែរ និងជនជាតិចិនមានពូជអម្បូរភាសាខុសគ្នាបានកើតមានទូលំទូលាយជាងសម័យមុនសង្គ្រាម។ អន្តរកម្មវប្បធម៌តាមរយៈអាពាហ៍ពិពាហ៍ ការរស់នៅលាយចម្រុះជាតិសាសន៍ និងចម្រុះអម្បូរបានធ្វើឱ្យភាសាខ្មែរនិងភាសាចិនលាយខ្មែរ បានក្លាយជាភាសាដែលមានតួនាទីសំខាន់មួយនាពេលបច្ចុប្បន្ន។ ឆ្លងកាត់សម័យសង្គ្រាមជាច្រើនទសវត្សរ៍បានធ្វើឱ្យជនជាតិចិន ពិសេសកូនចៅជំនាន់ក្រោយភាគច្រើនភ្លេចភាសាចិនរបស់ពូជអម្បូរខ្លួន។

ក្រៅពីភាសា ជំនឿសាសនា ប្រពៃណី និងទំនៀមទម្លាប់ រួមមាន ការបញ្ចុះសពតាមប្រពៃណីចិន ពិធីសែនព្រេន ការគោរពចំពោះដូនតាបុព្វការីជន បុណ្យចូលឆ្នាំចិន ឆេងម៉េង (ពិធីសែនផ្នូរដូនតា) សែនសំពះព្រះខែ ដង្ហែអ្នកតា ជាដើម គឺជាផ្នែកមួយដ៏មានឥទ្ធិពលនៃការពង្រឹងអត្តសញ្ញាណ និងជំរុញឱ្យមានសាមគ្គីភាពរវាងក្រុមជនជាតិចិននៅកម្ពុជាដែរ។

ជនជាតិចិននៅតាមតំបន់នានានៃប្រទេសកម្ពុជាភាគច្រើន បានសម្របខ្លួនទៅនឹងសង្គម-វប្បធម៌ខ្មែរ តាមរយៈការប្រតិបត្តិជំនឿ សាសនា ប្រពៃណីនិងទំនៀមទម្លាប់ខ្មែរ ដូចជាការរៀបការជាមួយជនជាតិខ្មែរដោយ អនុវត្តតាមពិធីទំនៀមទម្លាប់ខ្មែរ ធ្វើបុណ្យទានតាមរបៀបខ្មែរ ការចូលរួមពិធីសាសនានៅតាមវត្តអារាម ការប្រារព្ធពិធីបុណ្យផ្សេងៗតាមប្រពៃណីខ្មែរ និងរក្សានូវរបៀបរស់នៅតាមបែបខ្មែរ តាមរយៈការចូលរួមក្នុងពិធីបុណ្យសពនិងគោរពបូជាអារក្សអ្នកតាម្ចាស់ទឹកដីរបស់ប្រទេសកម្ពុជា។ ការលេចឡើងនៃពិធីបុណ្យសពតាមរបៀបខ្មែរ ដូចជាការតុបតែងក្តារមឈូសតាមរបៀបខ្មែរ និងដុតផ្ទះគំរូធ្វើពីក្រដាស់តាមរចនាបទផ្ទះខ្មែរ បានឆ្លុះបញ្ចាំងអំពីការសម្របខ្លួនទៅនឹងសង្គមនិងវប្បធម៌នៅលើទឹកដីដែលពួកគេកំពុងរស់នៅ។ ពិធីបុណ្យខ្លះបានបញ្ចូលទាំងប្រពៃណីចិន និងប្រពៃណីខ្មែរខ្លះរួមគ្នាផង។ នៅតំបន់ខ្លះគេបានបូជាសពតាមទំនៀមរបស់ខ្មែរ វាដូចគ្នានឹងជនជាតិខ្មែរខ្លះក៏បានបញ្ចុះសពតាមរបៀបចិនដែរ។ បច្ចុប្បន្ននេះមានជនជាតិភាគតិចចិននៅកម្ពុជាភាគច្រើន បានអះអាងថាពួកគេមានអត្តសញ្ញាណជាជនជាតិខ្មែរ ដោយហេតុពួកគេចេះនិយាយភាសាខ្មែរ ទទួលទានម្ហូបអាហារខ្មែរ ស្លៀកពាក់ប្រពៃណីខ្មែរនិងមានមុខរបរដូចជនជាតិខ្មែរជាដើម។

ជនជាតិភាគតិចចិនទទួលបានសិទ្ធិសេរីភាពគ្រប់យ៉ាង បើប្រៀបធៀបទៅសម័យកាលមុនៗ (១៩៧០-១៩៩៣) ដោយពួកគេមានសិទ្ធិក្នុងការថែរក្សានិងផ្សព្វផ្សាយអត្តសញ្ញាណវប្បធម៌ជនជាតិចិនបានតាមគ្រប់មធ្យោបាយ។ នៅក្នុងទស្សនៈជនជាតិភាគតិចចិន ការពង្រីកវិស័យអប់រំនិងការបណ្តុះបណ្តាលភាសាចិនជាអត្តិភាពដំបូងនិងប្រកបដោយសក្តានុពលបំផុតក្នុងការផ្ទេរនិងពង្រីកការប្រើប្រាស់ភាសាចិន និងចំណេះដឹងវប្បធម៌ទៅកូនចៅចិននៅកម្ពុជាជំនាន់ក្រោយៗ។ ក្រៅពីសាលារៀនចិនជាច្រើននៅតាមស្រុក ខេត្ត ក្រុង គេឃើញមាន វិទ្យាស្ថានខុងជឺ នៅរាជបណ្ឌិត្យសភាកម្ពុជា ក៏កំពុងធ្វើសកម្មភាពយ៉ាងសកម្មក្នុងការបណ្តុះបណ្តាលភាសាចិននិងការផ្សព្វផ្សាយវប្បធម៌ចិនដល់សិស្ស និស្សិត មន្ត្រីរាជការខ្មែរដែលចូលទៅសិក្សានៅទីនោះ។




ពិធីសម្ពោធស្លាកវិទ្យាស្ថានខុងជឺ ក្រោមអធិបតីភាព
ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង
ឯកឧត្តមបណ្ឌិត ហ្ស៊ី ជីងពីង អនុប្រធានាធិបតីចិន
កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ នៅរាជបណ្ឌិត្យសភាកម្ពុជា



ពិធីបវេសនកាលបើកថ្នាក់ភាសាចិន
សម្រាប់មន្ត្រីរាជការកម្ពុជាលើកដំបូង
ក្រោមអធិបតីភាព លោកជំទាវ ច័ន្ទ គឹមហង្ស
ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា និង
លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា
ប្រធានរាជបណ្ឌិត្យសភាកម្ពុជា កាលពីថ្ងៃទី២១
ខែមករា ឆ្នាំ២០១០ នៅរាជបណ្ឌិត្យសភាកម្ពុជា

## ៤-ភាពស្ទាត់ជំនាញក្នុងការធ្វើជំនួញ

អន្តោប្រវេសន៍ចិនភាគច្រើនស្ទើរតែគ្រប់សម័យកាលត្រូវបានទទួលស្គាល់ថាជាអ្នកមានទេពកោសល្យខាងការធ្វើជំនួញជួញដូរ។ ប៉ុន្តែអ្នកស្រាវជ្រាវខ្លះមានទស្សនៈថាភាពស្ទាត់ជំនាញខាងសេដ្ឋកិច្ចក្នុងចំណោមជនជាតិចិនទាំងឡាយគឺមិនមែនជាចរិតលក្ខណៈរបស់ពួកគេតាំងពីកំណើតនោះឡើយ។ ជាទូទៅពួកគេរៀនជំនាញនេះពីបទពិសោធន៍ដែលពួកគេបានជួបប្រទះពេលបានមករស់នៅលើទឹកដីថ្មី និងសមត្ថភាពក្នុងការកែច្នៃធម្មជាតិបានធ្វើឱ្យពួកជនជាតិចិនទាំងនោះពូកែធ្វើជំនួញ។ ម្យ៉ាងទៀតផែនការរបស់ពួកអាណានិគមលើវិស័យសេដ្ឋកិច្ច និងតម្រូវការប្រើប្រាស់កម្លាំងពលកម្ម ក៏ជាកត្តាកំណត់បានជំរុញឱ្យពួកជនជាតិចិនខិតខំស្វែងរកជំនាញខាងធ្វើជំនួញ។

ដោយសារតែភាពវៃឆ្លាតរបស់ក្រុមជនជាតិភាគតិចចិន ស្ទើរតែគ្រប់សម័យកាលពួកគេបានគ្រប់គ្រងវិស័យជំនួញគ្រប់ប្រភេទនស្រុកខ្មែរ ហើយសកម្មភាពជំនួញរបស់ពួកគេនៅតែបន្តរហូតសព្វថ្ងៃ។ តាំងពីសម័យមុនរហូតបច្ចុប្បន្នជនជាតិភាគតិចចិននៅតែមានតួនាទីសំខាន់ក្នុងវិស័យសេដ្ឋកិច្ចនៅកម្ពុជា។ ពួកគេបានកាន់កាប់ទីផ្សារសេដ្ឋកិច្ចទាំងនៅទីក្រុងនិងខេត្តសំខាន់ៗប្រហែល៩០% ខណៈប្រជាជនខ្មែរភាគច្រើននៅបន្តប្រកបរបរកសិកម្មដោយប្រើកម្លាំងកាយ។ តួនាទីរបស់ក្រុមជនជាតិភាគតិចចិនបែបនេះ បានធ្វើឱ្យជនជាតិខ្មែរហាក់មិនពេញចិត្ត

ទាល់តែសោះ។ នៅសម័យអាណានិគមបារាំងក្តី និងសម័យសង្គមរាស្ត្រនិយម សុទ្ធតែធ្លាប់មានគោលនយោបាយដាក់សម្ពាធលើជនជាតិចិនកុំឱ្យក្តោបក្តាប់របរកសិកម្មនិងវិស័យជំនួញ។ គោលនយោបាយគាបសង្កត់ខាងសេដ្ឋកិច្ចក៏បានអនុវត្តដូចគ្នាចំពោះជនជាតិចិនដែលរស់នៅក្នុងតំបន់មួយចំនួននៃអាស៊ីអាគ្នេយ៍។ ការកំណត់ផែនការផ្ទេរសកម្មភាពសេដ្ឋកិច្ចពីជនជាតិចិនទៅឱ្យម្ចាស់ស្រុកដែលមានចំណេះដឹងធ្វើជំនួញ បានក្លាយជាគោលនយោបាយមូលដ្ឋានរបស់រដ្ឋនីមួយៗចំពោះជនជាតិចិននៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

នៅកម្ពុជាជនជាតិភាគតិចចិនទាំង៥អម្បូរមានមុខរបរនិងរបៀបរស់នៅចិញ្ចឹមជីវិតខុសៗគ្នាទៅតាមពូជអម្បូរនីមួយៗនិងទៅតាមស្ថានភាពទីកន្លែងដែលគេរស់នៅ។ ជនជាតិភាគតិចចិនច្រើនបានធ្វើជំនួញនិងការលក់ដូរទំនិញទាំងលើគោកនិងលើទឹកតាំងពីសម័យកាលមុនបារាំងចូលស្រុកខ្មែរម្ល៉េះ (ឃីង ហុកឌី ២០០៧: ៥៦)។ ដោយភាពក្រីក្រនៅតាមទីជនបទជនជាតិខ្មែរតែងតែធ្លាក់ខ្លួនជំពាក់បំណុលចិនកាន់តែច្រើនឡើងៗ។ នៅទសវត្សរ៍ឆ្នាំ១៩៥០ ដោយការព្រួយបារម្ភពីកូនចៅរបស់ខ្លួន ចាស់ព្រឹទ្ធាចារ្យខ្មែរក៏បានអប់រំដាស់តឿនក្រើនរំឭកកូនខ្មែរឱ្យប្រឹងប្រែងប្រកបរបរទទួលទានចិញ្ចឹមជីវិតកុំឱ្យជំពាក់បំណុលជនជាតិចិន៖

| | | |
|---|---|---|
| *អួតទាំងបំពាន* | *ផឹកម៉្ងៃលុយមាន* | *ផឹកម៉្ងៃលុយអត់* |
| *ឯងចេះតែកិន* | *ចិនចេះតែកត់* | *ផឹកដល់កំណត់* |
| | *យកស្រែបញ្ចាំ។* | |
| *កំណើតផឹកស្រា* | *ផឹកផុតមេត្តា* | *ផឹកជ្រុលហួសមាឌ* |
| *អ្នកមួយផឹកស្ទើរ* | *ល្វីល្វើចេះឆ្លៀត* | *ម្យ៉ាងផឹកផុតមារយាទ* |
| | *ច្រើននៅខ្ញុំចិន។* | |
| *កែកទឹកពុះអុស* | *វាគុញវាគុះ* | *ចាក់កែវផឹកសិន* |
| *ស៊ូកែកខំអត់* | *សំពត់ខើចក្បិន* | *ទម្រាំបាយឆ្អិន* |
| | *ចិនដួសហៅស៊ី។* | |
| *ឆ្ងាញ់តែម្នាក់ឯង* | *ឆ្អែតហើយខំស្វែង* | *ខំលើកខំលី* |
| *ដងទឹកស្រោចគ្រប់* | *ស្រោចខ្ទឹមម្ទេសជីរ* | *ខ្ញុំចិនម៉្ងៃពីរ* |
| | *វិលទៅរាំងផ្ទះ។* | |

អត្ថបទការសែតក្នុងស្រុកខ្លះក្នុងសម័យអាណានិគម ក៏បានទទួលស្គាល់នូវគំនិតដ៏ប៉ិនប្រសប់ និងឧស្សាព្យាយាមរបស់ជនជាតិភាគតិចចិនមានតួនាទីជាគំរូសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា។ ជនជាតិខ្មែរតែងសរសើរថាជនជាតិចិនមកស្រុកខ្មែរដោយបាតដៃទទេគ្មានដើមទុនអ្វីទាល់តែសោះ ប៉ុន្តែតែពេលមកដល់ស្រុកខ្មែរមិនយូរប៉ុន្មានក៏បង្កើតបានមុខរបរនិងជំនួញធំៗបាន។ នេះក៏ជាគំរូសំខាន់ផងដែររហូតជំរុញឱ្យចាស់ទុំខ្មែរ លោកតាក្រម ង៉ុយ (ច្បាប់ក្រមង៉ុយ) បានអប់រំដាស់តឿនឱ្យកូនចៅខ្មែរគ្រប់ទីកន្លែងខិតខំរៀនសូត្រលេខនព្វន្ត ចេះធ្វើជំនួញចិញ្ចឹមជីវិតដូចចិន និងកុំឱ្យឈ្នួញចិនកេងប្រវ័ញ្ចបាន៖

| | |
|---|---|
| *ជនជាតិខ្មែរផេតគំនិត* | *ស៊ីមិនគិតមើលខុសត្រូវ* |
| *ជឿចិនរាល់ផ្លូវ* | *កេរ្តិ៍ម៉ែឪចិនអូសអស់។* |
| *ចិនមកពីស្រុកនាយ* | *មានសំពាយដារបស់* |
| *មិនទាន់ចេះខ្មែរសោះ* | *គ្មានកេរ្តិ៍កោះស្រែចំការ...* |

ជាការពិតជនជាតិខ្មែរក៏មានប្រាជ្ញាមិនអន់ជាងជនជាតិចិនឡើយ ប៉ុន្តែអ្វីដែលសំខាន់ការខិតខំធ្វើការដោយអំណត់និងការចេះរៀបចំរបៀបរបបសង្គមដែលខ្លួនរស់នៅឱ្យបានល្អ។ នៅក្នុងកំណាព្យខ្មែរ «ច្បាប់ប្រុស» (ច្បាប់ផ្សេងៗ ១៩៧៤:៣៤) ក៏បានរំឭកដល់កូនចៅខ្មែរថា៖

*ពីព្រឹកស្លៀកហូលជរ     ល្ងាចស្លៀកសខ្លះចងក្បិន*
*ពីព្រឹកត្បូកក្បាលចិន     ល្ងាចមិនទាន់ចិនដាក់ខ្នោះ។*
*ជួនកាលវាចងជើង     ព្យួរខ្ពស់ឡើងក្បាលដាំចុះ*
*ភ្នែកស្លឹងតឹងក្រញ៉ុះ     វាទាប្រាក់ឱ្យបានឆាប់។*
*មើលមុខល្អតិចអ្វី     មិនខ្មាស់ស្រីផ្សារឈរស្តាប់*
*មុខមិញដូចគេស្លាប់     មាត់ស្ងិញស្ងាញពេបដូចក្មេង។*
*ស្រែកថ្ងូរអេះអុយអើយ     អាចឹកអើយអាណិតលែង*
*អញរកប្រាក់ឱ្យឯង     ឱ្យអាចឹកស្អែកនេះបាន។*

តាមរយៈខ្លឹមសារកំណាព្យ ចាស់ទុំចង់ប្រៀនប្រដៅចំពោះជនជាតិខ្មែរកាលពីសម័យដើមឱ្យចេះគិត ចេះខ្មាស់អៀន និងរៀនសូត្រចំណុចល្អៗក្នុងការរៀបចំរបៀបរបបចិញ្ចឹមជីវិតពីជនជាតិចិនដែលគេមករស់នៅលើទឹកដីឯងហើយក្លាយជាម្ចាស់បំណុលរបស់ខ្មែរជាម្ចាស់ស្រុកទៅវិញ។ ទាំងនេះក៏ជាគតិមួយដែលជនជាតិខ្មែរបច្ចុប្បន្នគួតែត្រិះរិះពិចារណាផងដែរ។

## ៥-អន្តរវប្បធម៌ខ្មែរនិងចិន

វប្បធម៌ សិល្បៈ ម៉ូតសម្លៀកបំពាក់ របៀបរបបរស់នៅ និងភាសាខ្មែរ បានគ្របដណ្តប់លើក្រុមជនជាតិភាគតិចចិនអស់រយៈពេលជាច្រើនសតវត្សកន្លងទៅ។ ឥទ្ធិពលវប្បធម៌ចិនមកលើខ្មែរមានលក្ខណៈជាការខ្ចីគ្នាទៅវិញទៅមកក្នុងរយៈពេលដ៏យូរអង្វែង។ លោក ហង់រី ម៉ាហ្សាល់ (១៩៣៦) បានបញ្ជាក់ថាឥទ្ធិពលចិនមកលើសិល្បៈខ្មែរឃើញមានតាំងពីសម័យអង្គររហូតដល់ដើមសតវត្សទី២០ (ផេន្នី អេដ្វឺដ្ស ២០០៩ ទំ.២០៣)។ ចំណែកលោក វិចទ័រ ហ្គូលូប៊ឺវ (Victor Golubew 1924) បានសន្និដ្ឋានថា សិល្បករចិនប្រហែលជាបានឆ្លាក់ចម្លាក់នៅលើជញ្ជាំងនៃប្រាង្គមួយនៃប្រាសាទអង្គរវត្ត ដែលលោក វៀលមតត៍ (Wilmotte 1966) អះអាងថាចម្លាក់ទាំងនោះបានឆ្លាក់ឡើង ៤០០ឆ្នាំក្រោយពីការកសាងអង្គរវត្តដែលជាភស្តុតាងនៃការរីកដុះដាលសហគមន៍ចិននាសម័យនោះ។

ក្នុងភាសាខ្មែរមានខ្ចីភាសាចិនប្រើប្រាស់ប្រចាំថ្ងៃមួយចំនួនដែលទាក់ទងនឹងសម្លៀកបំពាក់ គ្រឿងសង្ហារឹម ម្ហូបអាហារ សំណង់អគារ ដែលជាសញ្ញាណបញ្ជាក់បន្ថែមទៀតពីឥទ្ធិពលចិនមកលើវប្បធម៌ខ្មែរ។ សម្លៀកបំពាក់ដែលតួល្ខោនបាសាក់ខ្មែរស្លៀកពាក់កាលពីមុនមានលក្ខណៈជាខ្មែររហូតដល់សតវត្សទី១៩ ប៉ុន្តែនៅសតវត្សទី២០ និងបច្ចុប្បន្ន សម្លៀកបំពាក់ទាំងនេះមានលក្ខណៈជារបៀបចិនច្រើនជាង (សម្លៀកបំពាក់ហ៊ីចិន)។

ក្រៅពីភាសា គេសង្កេតឃើញថាការប្រតិបត្តិប្រពៃណីនិងទំនៀមទម្លាប់ជនជាតិ បានជះឥទ្ធិពលខ្លាំងទៅលើផ្នត់គំនិតរបស់ជនជាតិខ្មែរទៅលើការទទួលយកនូវទំនៀមមួយចំនួនរបស់វប្បធម៌ចិនមកអនុវត្ត ដែលរួមមានការរៀបរៀបចំអាពាហ៍ពិពាហ៍ខ្មែរមានលាយឡំដោយពិធីបែបចិន ចូលរួមអបអរខ្លាំងក្លាក្នុងពិធីបុណ្យចូលឆ្នាំចិន ពិធីសែនផ្នូរ (ឆេងម៉េង) និងពិធីជាប្រពៃណីជនជាតិចិនផ្សេងៗទៀតជាច្រើន មិនត្រឹមតែជះឥទ្ធិពលចំពោះប្រជាជនសាមញ្ញៗប៉ុណ្ណោះទេ សូម្បីមន្ត្រីរាជការខ្មែរក៏ទទួលឥទ្ធិពលពីវប្បធម៌ចិនទាំងនេះដែរ។

ឆ្លងកាត់របត់ប្រវត្តិសាស្ត្រខ្មែរជាច្រើនដំណាក់កាល ក្រុមជនជាភាគតិចចិន ឬហៅថាកូនចៅចិន ឬខ្មែរកាត់ចិន បានបន្តពូជពង្សវង្សត្រកូលនៅលើទឹកដីខ្មែរបានគង់វង្សមកដល់សព្វថ្ងៃ។ ទោះបីនៅក្នុងសម័យកាលខ្លះ ពួកគេ

បានជួបប្រទះនូវការរើសអើងពូជសាសន៍ក៏ដោយ ក៏ពួកគេនៅតែអាចសម្របខ្លួនប្រែប្រួលទៅតាមកាលៈទេសៈ ធ្វើយ៉ាងណាដើម្បីអាចរស់នៅក្នុងរបបនីមួយៗបានសុខ និងអាចពូនផ្តុំពង្រីកពូជពង្សនិងអត្តសញ្ញាណវប្បធម៌របស់ពួកគេ។

បច្ចុប្បន្នគេសង្កេតឃើញថា មុខរបរនិងជំនួញពាណិជ្ជកម្ម ចាប់ពីអាជីវកម្មខ្នាតតូច មធ្យមដល់ឧស្សាហកម្មខ្នាតធំហាក់ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ក្រុមជនជាតិចិន ឬកូនចៅចិនកាត់ខ្មែរនៅប្រទេសកម្ពុជា។ ក្រៅពីជនជាតិចិនឬកូនចៅចិនដែលរស់នៅកម្ពុជា នៅមានអ្នកវិនិយោគទុនជនជាតិចិនធំៗជាច្រើនទៀតមកពីប្រទេសចិន បានចូលមករកស៊ីនៅកម្ពុជាក្នុងវិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ វិស័យកសិកម្ម ព្រៃឈើ សំណង់អគារ ។ល។ ដូច្នេះនៅកម្ពុជារហូតបច្ចុប្បន្ន ត្រូវបានគេមើលឃើញថា ជនជាតិចិននៅតែមានតួនាទីចម្បងក្នុងជីវិតសេដ្ឋកិច្ចរបស់កម្ពុជាដដែល។ ប៉ុន្តែទោះបីយ៉ាងណា គេមិនទាន់ដឹងទេថាការដាក់ទុនធ្វើជំនួញនិងការវិនិយោគរបស់ជនជាតិចិននៅកម្ពុជាទាំងអស់នោះ បានផ្តល់ផលប្រយោជន៍និងផលប៉ះពាល់ក្នុងទំហំប៉ុណ្ណាចំពោះបច្ចុប្បន្នភាពនិងអនាគតនៃសេដ្ឋកិច្ចនិងធនធានធម្មជាតិ វប្បធម៌នៅកម្ពុជា។ នេះជាចំណុចសំខាន់ដែលយើងជាខ្មែរត្រូវធ្វើការសិក្សានិងត្រួតពិនិត្យឱ្យបានច្បាស់លាស់ទៅថ្ងៃមុខ៕

## ឯកសារយោង

*វចនានុក្រមខ្មែរ* បោះពុម្ពដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧។
លី ធាមតេង *កំណត់ហេតុ ជីវ តាក្វាន់* ១៩៧៣។
ផេន្នី អេដ្វឺដ្ស «ដើមកំណើតនិងការវិវឌ្ឍនៃអត្តសញ្ញាណរបស់ជនជាតិចិននៅកម្ពុជាតាំងពីសម័យដើមនៃប្រវត្តិសាស្ត្ររហូតដល់ឆ្នាំ១៩៧០» នៅក្នុង៖ *ក្រុមជនជាតិភាគតិចនៅកម្ពុជា* មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ឆ្នាំ២០០៩។
ទា វ៉ាន់ និង នៅ សុខម៉ានី «សមាហរណកម្មទៅក្នុងសង្គមជាតិនិងការស្តារអត្តសញ្ញាណឡើងវិញ» នៅក្នុង៖ *ក្រុមជនជាតិភាគតិចនៅកម្ពុជា,* មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ឆ្នាំ២០០៩។
យឹង ហុកឌី *បណ្តាំតាមាស,* បណ្ណាគារអង្គរ បោះពុម្ពឆ្នាំ២០០៧។
ច្បាប់ក្រមង៉ុយ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
*ច្បាប់ផ្សេងៗ,* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៧៤
Jean Boisselier *Trends in Khmer Art*, Edited and translated into English version by Natasha Eilenberg and Melvin Elliott, New York, 1989.
W. E. Willmott “History and Sociology of the Chinese in Cambodia Prior to the French Protectorate” Reviewed work(s), *Journal of Southeast Asian History,* Vol. 7, No. 1 (Mar., 1966), London.
W. Willmott, *The Political Structure of the Chinese Community in Cambodia,* London, 1979.